# I- ផ្នែកការគណៈរដ្ឋមន្ត្រី

## ១. អនុក្រឹត្យ

*រាជធានីភ្នំពេញ ,ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៩៤*

### អនុក្រឹត្យលេខ ៦៤ អនក្រ
### ស្តីពីការបង្កើត ៣ កងពលតូចទ័ពព្រៃ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ វរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតអគ្គសេនាធិការដ្ឋានកងទ័ពជាតិកម្ពុជា ។
- ផ្អែកតាមសំណូមពរចាំបាច់ នៃការកសាងកងយោធពលខេមរភូមិន្ទ ចំពោះមុខ ។
- ផ្អែកតាមសំណើរបស់ឯកឧត្តមសហរដ្ឋមន្ត្រី ក្រសួងការពារជាតិ និង នាយអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ ។

### សំរេច

**មាត្រា ១ :** ត្រូវបានបង្កើត ៣ កងពលតូចទ័ពព្រៃ ស្ថិតនៅក្រោមការដឹកនាំបញ្ជាផ្ទាល់របស់អគ្គសេនាធិការដោយយកសញ្ញាសំគាល់ កងពលតូចលេខ ១ ២ ៣ ទ័ពព្រៃ ។

**មាត្រា ២ :** រចនាសម្ព័នចាត់តាំង ភារកិច្ច និង សិទ្ធិរបស់កងពលតូចទ័ពព្រៃ អាស្រ័យដោយ អគ្គសេនាធិការកំណត់ ។

**មាត្រា ៣ :** ប្រគល់ជូនអគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទធ្វើការកំណត់ភារកិច្ច និង ពេលវេលាជាក់ស្តែងក្នុងការរៀបចំកងពលតូចទ័ពព្រៃនីមួយៗ ខាងលើ ។

**មាត្រា ៤ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការ នៃ កងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះដែលចូលជាធរមានចាប់តាំងពីថ្ងៃ ឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

*រាជធានីភ្នំពេញ ,ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៩៤*

## អនុក្រឹត្យលេខ : ៦៥ អនក្រ

## ស្តីពីការរៀបចំឃុំ ស្រុក ក្នុងខេត្តបន្ទាយមានជ័យ

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា ជាពិសេសមាត្រា ១២៦

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-តាមសំណើសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានបង្កើតឃុំថ្មីចំនួនបី ក្នុងស្រុកថ្មពួកគឺ :

១-ឃុំគោកកបិន មានចំនួនប្រាំបួនភូមិ ដែលកាត់យកប្រាំពីរភូមិ របស់ឃុំផ្គាំ គឺ ÷ ភូមិដី ភូមិស្ពោ ភូមិទ្រាស ភូមិគោកកបិន ភូមិតាសៀវ ភូមិជន្លះដៃ ភូមិតាត្រៃ និងកាត់យកពីរភូមិរបស់ឃុំភូមិថ្មី គឺភូមិព្រះឈរ និងភូមិគោកខ្ពស់ ។

២-ឃុំគំរូមានបួនភូមិ ដែលកាត់យកបីភូមិរបស់ឃុំថ្មពួក គឺ ភូមិតាយឹង ភូមិអណ្តូងខ្លុង ភូមិគំរូ និងកាត់យកភូមិកណ្តាល របស់ឃុំគោករមៀត ។